**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ខេត្តកែប-ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៦៖ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម** ចុះសួរសុខទុក្ខប្រជាពលរដ្ឋ និងពិនិត្យការដ្ឋានជីស្រះទឹក នៅឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។



*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៦ នេះដែរ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានឆ្លៀតពេលវេលាឈប់សំរាកផ្ទាល់ខ្លួនចុះជួយមូលដ្ឋានខេត្តកំពតនិងបានចូលរួមពិនិត្យស្ថានភាពកង្វក់ទឹកសមុទ្រយ៉ាងយកចិត្តទុកដាក់បំផុត ដោយមិនគិតពីការនឿយហត់ក្នុងការបម្រើជាតិប្រជាជនឡើយ។

ខាងក្រោមនេះ ជាប្រសាសន៍បញ្ជាក់ទឹកចិត្តគោរពស្រលាញ់ និងគិតគូរពីសុខទុក្ខប្រជាពលរដ្ឋយ៉ាងពិតប្រាកដ របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី៖**

"ថ្ងៃនេះ ហាក់ដូចជាពោរពេញដោយរឿងដែលខ្ញុំត្រូវដោះស្រាយបន្ទាន់ ដើម្បីសុខុមាលភាពប្រជាជន៖

**១.** សហការជាមួយក្រសួងបរិស្ថាន និងអាជ្ញាធរ ខេត្តកែបអំពីស្លែសមុទ្ររីកជាព្រាំ ដោយសារធាតុអាកាសតាមមាត់សមុទ្រឡើងក្តៅខ្លាំង ។ បាតុភូតនេះធ្លាប់កើតមាន នៅច្រើនប្រទេស ។ វាដូចជាផ្ការីកខុសរដូវអញ្ចឹង ។ ពេលស្លែរីកច្រើន ទឹកសមុទ្រប្រែពណ៌ពីបៃតងទៅលឿង កកើតជាតិammoniac ច្រើន ដែលស្រូបoxygen នៅក្នុងទឹកសមុទ្រ ។ ត្រីដែលហែលទៅប៉ះព្រាំនោះ គឺស្ទះខ្យល់ងាប់តែម្តង ។ ចំពោះមនុស្សដែលហែលប៉ះព្រាំនោះ អាចកើតរមាស់ តែបើគេជ្រុលលេបទឹកព្រាំ យើងមិនដឹងប៉ះពាល់សុខភាពគេយ៉ាងណាទេ ។ ដូច្នេះ រាជរដ្ឋាភិបាល តាមការណែនាំផ្ទាល់ពីសម្តេចតេជោ បានសំរេចអំពាវនាវឱ្យផ្អាកការចុះងូតទឹកសមុទ្រ និងហូបគ្រឿងសមុទ្រ។ យើងកំពុងយកទឹកសមុទ្រទៅវិភាគនៅមន្ទីរពិសោធន៍របស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រសួងបរិស្ថាន ។ ការប្រកាន់វិធានការការពារដល់អាយុជីវិតប្រជាជនយើង ពិតជាមានប៉ះពាល់ដល់អាជីវកម្មនានាក្នុងខេត្តកែបមួយរយៈខ្លី តែវាប្រសើរជាងបណ្តែតបណ្តោយឱ្យប្រជាជនយើងពុលម្ហូបអាហារ។ បាត់ម៉ូយ ២ឬ៣ថ្ងៃ ប្រសើរជាជាងបាត់ម៉ូយជារៀងរហូត។

**២.** ចុះពិនិត្យការដ្ឋានជីកស្រះទឹកជូនប្រជាជនចំនួន ៧កន្លែងនៅឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។

**៣.** ចុះសួរសុខទុក្ខអាជីវករផលិតអំបិលនៅឃុំអង្កោល។

**៤.** ចុះពិនិត្យទីតាំងសាងសង់អាគារសិក្សាមួយខ្នងមាន៥ បន្ទប់នៅសាលាបឋមសិក្សាចំការស្វាយ ភូមិចំការបីឃុំពងទឹកស្រុកដំណាក់ចង្អើរ។

**៥.** ចូលទស្សនាចំការម្រេចមួយកន្លែងនៅភូមិខាងលើ។

ហត់នឿយមែន តែពេលឃើញប្រជាជនរីករាយចំពោះសមិទ្ធផលដែលយើងបានកសាងសំរាប់គាត់និងកូនគាត់គឺភ្លេចនឿយហត់អស់រលីង!"

**ចម ប្រសិទ្ធ**

*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

១. **ឯកឧត្តមទេសរដ្ឋមន្ត្រី** សហការជាមួយក្រសួងបរិស្ថាន និងអាជ្ញាធរ ខេត្តកែបអំពីស្លែសមុទ្ររីកជាព្រាំ ដោយសារធាតុអាកាសតាមមាត់សមុទ្រឡើងក្តៅខ្លាំង៖







*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

២. **ឯកឧត្តមទេសរដ្ឋមន្ត្រី** ចុះពិនិត្យការដ្ឋានជីកស្រះទឹកជូនប្រជាជនចំនួន ៧កន្លែងនៅឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែបៈ





៣. **ឯកឧត្តមទេសរដ្ឋមន្ត្រី**ចុះសួរសុខទុក្ខអាជីវករផលិតអំបិលនៅឃុំអង្កោលៈ






៤. **ឯកឧត្តមទេសរដ្ឋមន្ត្រី**ចុះពិនិត្យទីតាំងសាងសង់អាគារសិក្សាមួយខ្នងមាន៥ បន្ទប់នៅសាលាបឋមសិក្សាចំការស្វាយ ភូមិចំការបីឃុំពងទឹកស្រុកដំណាក់ចង្អើរៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

៥. **ឯកឧត្តមទេសរដ្ឋមន្ត្រី** ចូលទស្សនាចំការម្រេចមួយកន្លែងនៅភូមិចំការបើឃុំពងទឹកស្រុកដំណាក់ចង្អើរ៖

